# ១. តើអ្វីជាWordPress?

WordPress គឺជាប្រព័ន្ធគ្រប់គ្រងមាតិការដែលគេប្រើសម្រាប់បង្កើតគេហទំព័រ និងបង្កើតប្លុក។ ប្លុក WordPressគឺជាប្លុកដែលពេញនិយមជាងគេ ពីសំណាក់អ្នកប្រើប្រាស់ ព្រោះវាផ្តល់ភាពងាយ ស្រួល ក្នុងការបង្កើតគេហទំព័រផ្ទាល់ខ្លួនមួយបានដោយមិនចាំបាច់ចេះកូដនោះទេ។ យើងប្រើប្លុក WordPress ដើម្បីរាប់អានមិត្តភក្តិនិងចែករំលែកចំនេះដឹងគ្នាទៅវិញទៅមក។

ខាងក្រោមនេះខ្ញុំនឹងលើកពីរបៀបបង្កើតប្លុក WordPress ដល់មិត្តទាំងអស់គ្នា ប៉ុន្តែ មុន នឹងយើង បង្កើត យើងត្រូវដឹងថាខ្លួនឯងថាតើយើងបង្កើតប្លុកនេះក្នុងគោលបំណងអ្វី ដូចជា ដើម្បីចែករំលែក បទពិសោធន៍ជីវិត ចែករំលែកពីចំនេះដឹងផ្នែកពត៌មានវិទ្យា ឬអំពី អក្សរសាស្រ្ត ខ្មែរ ជាដើម។ បន្ទាប់ មក ទើបយើងរៀបចំឯកសាររបស់យើង និងបែងចែកវា ទៅតាម ប្រភេទ និមួយៗ។ ការធ្វើបែបនេះ គឺ ផ្តល់ ភាពងាយស្រួលដល់យើងនៅពេលយើងចាប់ផ្តើមបង្កើត ។

# ២. ប្រវត្តិរបស់WordPress

ខាងក្រោមនេះគឺជាកំណែផ្សេងគ្នានៃប្រវត្តិរបស់WordPress តាមលំដាប់លំដោយពីមុន រហូតដល់សព្វថ្ងៃ។

| Version | Release Date | Musician | Change Log | Announcement | DB Version |
|---|---|---|---|---|---|
| 1.0 | January 3 2004 | Miles Davis | Changelog | Blog | |
| 2.0 | December 26 2005 | Duke Ellington | Changelog | Blog | 3441 |
| 3.0 | Jun 17 2010 | Thelonious Monk | Changelog | Blog | 15260 |

Planned Version

| Version | Planned Release Date | Remarks |
|---|---|---|
| 3.6 | April 29, 2013 | |
| 3.7 | Middle of 2013 | |
| 3.8 | Late 2014 | |

## ៣.របៀបតម្លើងWordPressនឹងបង្កើតDatabase

ដើម្បីតម្លើង WordPress នៅលើកុំព្យូទ័ររបស់យើងបាន យើងត្រូវមាននូវៈ

- Wamp Server ឬ Xampp  គឺជាកម្មវិធីមួយដែលអាចទ្រទ្រង់Websiteរបស់យើងបានដោយពុំបាច់មានInternet។
- កញ្ចាប់ WordPress Package (www.wordpress.org).

ដំបូងយើងត្រូវតម្លើងWamp Server សិន។បន្ទាប់ពីតម្លើង Wamp Serverចប់សព្វគ្រប់ យើងត្រូវបើកកម្មវិធី Wamp Server ឲ្យមានពណ៌បៃតងទើបយើងអាចប្រើប្រាស់ WampServer  បាន។




បន្ទាប់ពីបានដំណើរការ  WampServer ហើយត្រូវ ពន្លាកញ្ចប់ WordPress Package ដាក់ចូលទៅក្នុង C:\Wamp\WWW




បន្ទាប់មកទៀតយើងត្រូវចុចលើរូប  WampServer  ->Localhost  នោះវានឹងបង្ហាញផ្ទាំងBrowser  របស់យើងដែលទីតាំងរបស់ស្ថិតនៅLocalhost។

➢ ចំណាំៈបើយើងចុច WampServer ->Localhostហើយវាមិនបង្ហាញទីតាំងlocalhost យើងត្រូវវាយ **127.0.0.1** វិញ ដោយសារវាគុង PortជាមួយLocalhost។

បន្ទាប់មកទៀតសូមចុចលើ WordPress Packageរបស់យើង។វានិងបង្ហាញដូចខាងក្រោម




ត្រង់ចុចនេះគឺជាចំនុចដែលយើងកំពុងតម្លើWordPressចូលទៅក្នុងMachineរបស់យើង

សូមចុចCreate a Configuration File->Let's go មុននឹងបំពេញពត៌មានយើងត្រូវបង្កើតDatabase ជាមុនសិន។

- របៀបបង្កើតDatabase

ចុចលើURL bar វាយ 127.0.0.1/phpmyadmin ពេលនោះវានឹងបង្ហាញផ្ទាំង**phpmyadmin**

បន្ទាប់មកវាយឈ្មោះDatabase ដែលយើងនឹងបង្កើត រួចចុច Createជាការស្រេច។



បន្ទាប់មកទៀត យើងចូលទៅបំពេញពត៌មាននៃការតំលើងWordPress ដូចខាងក្រោម៖




1. Database Name =ដាក់ឈ្មោះDatabase ដែលយើងទើបនឹងបង្កើត
2. User name = Root ដោយសារយើងប្រើវាជាលក្ខណៈLocalhost
3. Password = None
4. Database Host = Localhost
5. Table Prefix =WP_

ហើយសូមចុចSubmit button បន្ទាប់មកទៀតសូមធ្វើការបញ្ចូលពត៌មានដែលទាក់ទងទៅនឹងWebរបសយើង។



ពត៏មានទាំងនេះមានដូចជា៖

- Site Title   គឺជាចំនងជើង ឬឈ្មោះវេបសាយរបស់យើង ឧ.WordPress
- Username គឺជាឈ្មោះម្ចាស់វេបសាយ
- Password  គឺជាលេខសម្ងាត់ដែលអនុញ្ញាត់ឲ្យយើងចូលធ្វើការកែប្រែវេបសាយរបស់យើង (សូមជៀសវាងការដាក់លេខសម្ងាត់ដែលងាយស្រួលទាយ!)
- Email     គឺត្រូវបំពេញEmail របស់អ្នកប្រើប្រាស់។បន្ទាប់មក់ចុច Install WordPress នោះការតម្លើងវេបសាយត្រូវបានបញ្ចប់ ហើយចុច Login។




សូមធ្វើការបញ្ចូលឈ្មោះម្ចាស់វេបសាយ នឹង លេខសម្ងាត់ ហើយចុច Login។

ការតម្លើងវេបសាយត្រូវបានបញ្ចប់ជាស្ថាពរ

# ៤.របៀបតម្លើង WordPress Theme

WordPress មានTheme ជាច្រើនដែលមានភាពស្រស់ស្អាត ហើយរស់រវើក ហើយយើងអាចធ្វើការជ្រើសរើសយកមកប្រើប្រាស់តាមចំនង់ចំនូលចិត្ត។ដើម្បីតម្លើងចូរអនុវត្តដូចខាងក្រោម៖

1. ចូលទៅកាន់Menu មួយដែលមានឈ្មោះថា Appearance ហើយជ្រើសយក Theme
2. បន្ទាប់មកទៀត ចុចInstall Themes ហើយ

Upload ហើយចុច Browse ទៅកាន់ទីកន្លែងតាំង Theme របស់យើង ហើយជ្រើសយកដោយចុច Open ហើយចុចUpload ទៅកាន់វេបសាយរបស់យើង សូមចុច Preview ដើម្បីពិនិត្យមើលសិន ឬ Active ដើម្បីប្រើប្រាស់ Theme នោះជាការស្រេច។




# ៥.របៀបប្តូរផ្ទាំងBackground

ដើម្បីបន្ថែមសោភ័ណ្ឌភាព ឲ្យវេបសាយរបស់យើងនោះ គួរតែប្តូរផ្ទាំងBackground ដើម្បីប្តូរសូមចូលទៅ Appearance បន្ទាប់Background។បន្ទាប់មកចុចBrowse ទៅរករូបភាពដែលយើងចង់ដាក់ជាផ្ទៃខាងក្រោយ។

- ❖ ចំណាំ៖បើសិនយើងយករូបភាពដែលមានទំហំធំមកធ្វើជាផ្ទៃនោះ វាអាចធ្វើឲ្យវេបសាយរបស់យើងយឺត! ដូចនេះសូមធ្វើការជ្រើសរើសរូបភាពដែលមានទំហំតូចល្មម។



## ៦. របៀបប្តូរHeader

ជាការពិតណាស់សម្រាប់វេបសាយនីមួយៗមានភាពទាក់ទាញអាស្រ័យលើក្បាលទំព័រ(Header) តែការប្តូរនេះគឺអាស្រ័យលើTheme របស់យើងផងដែរ ចំពោះThemes ខ្លះមិនអនុញ្ញាតឲ្យប្តូរទេ។
ដើម្បីប្តូរក្បាលទំព័រយើងត្រូវ ចូលទៅកាន់ Appearance ចុចលើ Header។




ហើយដើម្បីប្តូរនោះយើងត្រូវចុចលើ Browse រួចហើយទៅរកទីតាំងរបស់រូបភាពនោះ ហើយចុច Open ហើយជាចុងក្រោយចុច Upload Button បន្ទាប់ពីUpload បានហើយ ចុចលើ Save Button ជាការស្រេច។

## ៧. របៀបបង្កើតCategories

ការបង្កើតCategories គឺដើម្បីរៀបចំអត្ថបទរបស់យើងឲ្យមានលក្ខណៈជាក្រុម នឹង មានសណ្តាប់ធ្នាប់ នឹងងាយស្រួលដល់អ្នកទស្សនា។ ដើម្បីបង្កើតCategories យើងត្រូវចូល Posts ហើយចុច Categories




- Name =បំពេញឈ្មោះ Categories របស់យើង
- Slug =បំពេញឈ្មោះដូចឈ្មោះCategories របស់យើង

បន្ទាប់ពីបានបំពេញសព្វគ្រប់ហើយ សូមចុចប៊ូតុង Add New Categories ពេលនោះ Categories ថ្មីរបស់យើងបានចូលទៅ ប្រអប់ខាងស្តាំ។ ហើយប្រសិនបើ Categories ដែលយើងបានបង្កើតខុសនោះ យើងអាចធ្វើការកែប្រែបានភ្លាម ដោយគ្រាន់តែចុច៖




- Edit កែប្រែ
- Quick Edit កែប្រែតែ Categories Name នឹង Slug
- Delete លុបCategories ចោល
- View មើល Categories ក្នុងវេបសាយរបស់យើង

## ៨. របៀបPosts អត្ថបទ

ដើម្បីធ្វើការPost អត្ថបទបានយើងត្រូវចូលទៅកាន់ Post Menu ហើយ ចុចលើ Add New ពេលនោះវានឹងបង្ហាញប្រអប់មួយ ដើម្បីឲ្យយើងសសេរអត្ថបទនោះ ហើយព្រមទាំងមានឧបករណ៍ជាច្រើន ក្នុងការប្រើប្រាស់។




បន្ទាប់ពីយើងសសេររួចសូមដាក់វាក្នុងCategories ណាមួយ ឬក៏យើងអាចប្រកាស់ Categories ថ្មីដោយគ្រាន់តែចុច Add New Category ហើយ យើងគប្បីTag អត្ថបទនោះផងដែរឧទាហរណ៍ថាអត្ថបទនោះទាក់ទងនឹង Software ដូចនេះយើងត្រូវវាយ Software ហើយចុច Add។ដើម្បីឲ្យអត្ថយើងមានរូបភាពពីមុខ នោះយើងគប្បីដាក់ Featured Image ហើយដើម្បីដាក់នោះគ្រាន់តែចុច Set Featured Image ហើយជ្រើសយករូបភាពពីLibrary ជាការស្រេច។




## ៩. ការកំណត់ការបង្ហាញចំនួនអត្ថបទ

ជាទូទៅនៅពេលដែលយើងPost អត្ថបទគឺវាតែងតែបង្ហាញនៅទំព័រដើម តែបើយើងPost អត្ថបទកាន់តែច្រើនទៅៗនោះ វាបណ្តាលវេបសាយរបស់យើងក៏កាន់តែយឺតដែរ ដូចនេះយើងគប្បីកំណត់ចំនួនអត្ថបទឲ្យបានច្បាស់លាស់។




ដើម្បីកំណត់យើងត្រូវចូលទៅ Setting Menu ហើយចុច Reading




ត្រង់ **Blog pages show ate most :** គឺចំនួនអត្ថបទក្នុងទំព័រដើម។ពេលកំណត់ហើយចុចប៊ូតុង Save Change ជាការស្រេច។

# ១០. របៀបតម្លើងPlugin

Plugin គឺជាកម្មវិធីបន្ថែមទៅលើវេបរបស់យើង ដែលធ្វើឲ្យវេបរបស់យើងមានលក្ខណ:ស្រស់ស្អាតងាយ ស្រួលប្រើប្រាស់ ទាក់ទាញ នឹងបន្ថែមទៅលើមុខងារមួយចំនួនទៀត Themeរបស់យើងពុំមាន។ដើម្បីចូលទៅតម្លើង Plugin ចូលទៅ Plugin Menu-> Add New




បើសិនជាយើងស្គាល់ឈ្មោះPlugin យើងគ្រាន់តែវាយឈ្មោះ ហើយចុចលើប៊ូតុងSearch Plugin នោះយើងនឹងឃើញមាន Plugin នោះហើយចុចលើប៊ូតុង Install ជាការស្រេច។តែបើសិនជាយើងមានPlugin ស្រេចហើយចង់តម្លើងនោះ គឺគ្រាន់តែចុចលើ Upload->Choose File->Install Now ជាការស្រេច។

# ១១ .បន្ថែមContact Us Page

ជាការចាំបាច់ណាស់ សម្រាប់ការដាក់ Page Contact Us ដើម្បីឲ្យអ្នកទស្សនា ធ្វើការទំនាក់ទំនង មកយើងដែលជាម្ចាស់វេប ដើម្បីជាការរិះគន់ ការស្នើរសុំ ហើយជាពិសេសទៅទៀតនោះគឺ ការទំនាក់ទំនងដើម្បីផ្សព្វផ្សាយពាណិជ្ជ។

ដើម្បីដាក់ Contact Us Page គឺយើងត្រូវតម្លើងPlugin មួយគឺឈ្មោះថា Si Contact Form បន្ទាប់តម្លើងយើងត្រូវទៅចម្លងយក(Copy) Short Code របស់Form ដែលយើងត្រូវការ



បន្ទាប់មកទៀតយើងត្រូវបង្កើតPage មួយដែលមានឈ្មោះថា Contact Us ហើយដើម្បីបង្កើតPage គឺយើងចូលទៅPage Menu->Add New




ហើយមកបិទផ្ទាប់នៅ Page របស់យើង




ហើយបន្ទាប់មកទៀតយក Contact Page របស់យើងទៅបង្ហាញនៅលើ Menu Tab ដែលស្ថិតនៅលើវេបរបស់យើង គឺគ្រាន់តែបន្ថែមPage របស់យើងទៅ Menu របស់យើង ហើយ Save ជាការស្រេច។









# ១៧.បន្ថែមប៊ូតុងចែករំលែកទៅអត្ថបទ




ប៊ូតុងចែករំលែក គឺជាប៊ូតុងដែលអាចឲ្យអ្នកទស្សនាចែករំលែកអត្ថបទរបស់យើងទៅកាន់មិត្តភក្តិដទៃទៀត តាមរយៈបណ្តាញសង្គមជាច្រើន ដូចជា Facebook,Google+,Twitter និង ជាច្រើន ទៀត។

ដើម្បីដាក់ប៊ូតុងនេះយើងត្រូវតម្លើងPlugin មួយឈ្មោះថា “Twitter Facebook Social Share” នៅពេលតម្លើងចប់សព្វគ្រប់យើងត្រូវទៅកែប្រែចំនុចមួយចំនួនដូចជា៖




1. ទីតាំងរបស់បូតុង
2. ទំរង់របស់ប៊ូតុង
3. កូដពណ៌របស់ផ្ទៃខាងក្រោយប៊ូតុង
4. អាយឌីTwitter

Save ជាការស្រេច។

# ១៣. របៀបដាក់រូប អាយខុន




រូប អាយខុន គឺជារូបតំណាងឲ្យប្លុករបស់យើង ដែលវាបង្ហាញនៅលើ Title Bar និង Address Bar ។ខាងក្រោមនេះគឺជារបៀប នៃការដាក់រូប អាយខុន គឺដំបូងគឺត្រូវតំលើងPlugin មួយមានឈ្មោះថា All in One Favicon។ បន្ទាប់ពីតម្លើងហើយ យើងត្រូវកែប្រែចំនុចមួយចំនួន ដូចជា៖




ចុច**Upload** ជ្រើសយករូបភាពដែលយើងចង់ដាក់ហើយ ចុច**Save** ជាការស្រេច។

# ១៤. របៀបដាក់ចំនួនអ្នកកំពុងទស្សនា

មានគេហទំព័រជាច្រើនដែលផ្តល់សេវាកម្មរាប់ចំនួន អ្នកកំពុងទស្សនា លើប្លុក ឬ គេហទំព័រ ដោយឥតគិតថ្លៃ។ តែពេលនេះ ខ្ញុំសូមបង្ហាញពីគេហទំព័រមួយ គឺ Histats.com ដែលផ្តល់ឲ្យយើងដឹងពីចំនួនអ្នកកំពុង ទស្សនា , ចំនួនអ្នកទស្សនាសរុប និង បង្ហាញពីចំនួន ទំព័រដែលបានទស្សនា ទៀតផង។

១. មុនដំបូងយើងចូលទៅកាន់គេហទំព័រ Histats.com ដើម្បីធ្វើការចុះឈ្មោះ

២. បន្ទាប់ពីធ្វើការចុះឈ្មោះរួចហើយ យើងចូលទៅកាន់ Control Panel របស់យើង រួចចុចលើ **Add a website**




៣. បន្ទាប់មកយើងវាយ អាស័យដ្ឋាន របស់ប្លុករបស់យើងចូល និង បំពេញពត៌មានផ្សេងៗដូចរូបខាងក្រោម




៤. បន្ទាប់មក យើងចុចចូលលើ website ដែលយើងទើបតែបង្កើត




៥. ពេលនោះវានឹងបង្ហាញផ្ទាំងមួយដែលអាចឲ្យយើងដឹងពត៌មានជាច្រើនពីគេហទំព័ររបស់យើង តែ ដើម្បីបង្កើត Counter យើងចុចលើ Counter CODE។




៦. បន្ទាប់មក យើងចុចលើ Add new counter




៧. ពេលនោះ វានឹងបង្ហាញទំរង់ Counter ជាច្រើនដើម្បីឲ្យយើងធ្វើការជ្រើសរើសទៅតាមដែលយើងចង់បាន។ បន្ទាប់ពីយើងស្រឡាញ់លើ Counter ណាមួយហើយ យើងចុចលើវា




៨. ដំបូង Counter របស់យើងមានតែ រាប់ចំនួនអ្នកកំពុងទស្សនាទេ ដូចនេះដើម្បីបន្ថែមមុខងារផ្សេង ៗ យើងគ្រាន់តែជ្រើសរើសបន្ថែម ដូចរូបខាងក្រោម រួចចុច ប៊ូតុង **Save**




៩. បន្ទាប់ពី បង្កើត Counter រួច យើងចុចលើវា ដើម្បីយកកូដវាមកដាក់លើប្លុករបស់យើង។

១០. វាផ្តល់ជំរើសកូដជាច្រើនឲ្យយើង តែដោយសារតែនៅក្នុង WordPress វាមិនអនុញ្ញាតឲ្យយើង ប្រើប្រាស់កូដ JavaScript ដូចនេះយើងជ្រើសរើសកូដដែលគ្មាន JavaScript។ បន្ទាប់មកយើង Copy កូដដូចដែលខ្ញុំបាន Selected ដូចរូបខាងក្រោម ។




១១. បន្ទាប់មកយកកូដនោះ ទៅ Past នៅក្នុង វិដជិត(អត្ថបទ) នៅក្នុង ប្លុករបស់យើង។




បន្ទាប់ពីការរួចហើយ ចុចលើប៊ូតុង **រក្សាទុក** ជាការស្រេច។




# ១៥. របៀបបង្កើតUser ថ្មី

ដោយសារតែ វាមានភាពពិបាក និងយឺតយ៉ាវ ក្នុងការបន្ថែមនូវអត្ថបទដូចនេះហើយ យើងត្រូវការបង្កើតឲ្យមានអ្នកប្រើប្រាស់ច្រើន លើវេបសាយតែមួយ។ ដើម្បីបន្ថែមអ្នកប្រើប្រាស់យើង ត្រូវចូលទៅកាន់ Users ->Add New User




បន្ទាប់មកទៀតត្រូវបំពេញពត៌មានមួយចំនួនដូចជា៖




UserName :ឈ្មោះអ្នកប្រើប្រាស់ថ្មី

Email :សារអេឡិចត្រូនិចរបស់អ្នកប្រើប្រាស់

Password :លេខសម្ងាត់របស់អ្នកប្រើប្រាស់ក្នុងការចូលកែប្រែ ឬ បន្ថែមអត្ថបទ

ហើយអ្វីដែលសំខាន់មួយទៀតនោះគឺសិទ្ធិ(Role)




## សង្ខេបរបស់សិទ្ធិ

- Super Admin – អ្នកដែលអាចគ្រប់គ្រងទៅលើការកែប្រែ និងអាប់ដេតវេបសាយទាំងអស់
- Administrator – ដូចទៅនឹងsuper Admin ដែរ
- Editor – អាចត្រឹមតែគ្រប់គ្រងអត្ថបទ នឹងអត្ថបទរបស់user ផ្សេងទៀត
- Author – អាចត្រឹមតែគ្រប់គ្រងអត្ថបទរបស់ខ្លួនឯង
- Contributor – អាចត្រឹមតែគ្រប់គ្រងអត្ថបទរបស់ខ្លួនឯង តែមិនអាចបង្ហោះផ្សាយវាទេ
- Subscriber – អាចត្រឹមតែគ្រប់គ្រងProfile របស់ខ្លួន

# ១៦. របៀបកែប្រែក្នុងGeneral




Site Title: ចំនងជើង ឬឈ្មោះSite របស់យើង

Tageline: ពិពណ៌នាពីឈ្មោះSite

Email: Email របស់អ្នកប្រើប្រាស់

New User Default Role: កំនត់សិទ្ធិរបស់អ្នកប្រើប្រាស់ជាDefault

Timezone : កំនត់តំបន់ពេលវេលា

Date Format: កំនត់ទម្រង់ថ្ងៃខែឆ្នាំ

# ១៧. របៀបកំនត់ Parmalinks




នៅពេលខ្លះយើងអាចធុញទ្រាន់ ពេលURL address របស់យើងចេញ ?cat=3,... ពេលនេះខ្ញុំនឹងបង្ហាញពីការប្តូរទាំងនេះ។ដំបូងយើងត្រូវចូលក្នុង Setting Menu-> Permalinks




- Default :ជាធម្មតាលក្ខណ: ?cat=1,...
- Day and Name :ជាលក្ខណ:មានថ្ងៃខែឆ្នាំ
- Month and Name :បង្ហាញលក្ខណ:ជាខែ
- Numeric :បង្ហាញលក្ខណ:តួរលេខរបស់អត្ថបទ
- Post Name :បង្ហាញលក្ខណ:បង្ហាញឈ្មោះ(គេតែប្រើ)
- Custom Struture :លក្ខណ:ដែលយើងកំណត់ដោយខ្លួនឯង

# ១៨.ការប្រើប្រាស់Library

ក្នុងLibrary គឺឃ្លាំង ស្តុងទិន្នន័យរបស់Site របស់យើង ដែលទិន្នន័យទាំងនោះមានដូចជា រូបភាព សម្លេង វីដេអូ នឹង ឯកសារដទៃទៀតដែលយើងបាន ដាក់ចូល(Upload) ក្នុងSiteរបស់យើង ហើយយើងអាចធ្វើការកែប្រែរ លុប និងមើល ទៅលើឯកសារទាំងនោះ។




## ១៩.ការប្រើប្រាស់Black Studio TinyMCE

ជាការពិតណាស់ វាពិតជាពិបាកណាស់នៅពេលដែលយើង ចង់សសេរកូដផ្សេងៗ ឬក៏ចង់ដាក់រូបភាព ចំរៀងនៅក្នុង Sidebar ជាឧទាហរណ៍ នៅពេលដែលយើងចង់ដាក់រូបភាព យើងតែងតែទៅសសេរនៅក្នុងកម្មវិធីផ្សេងសិនដូចជា៖ Dreamweaver, Notepad++,...ទើបយើង ចម្លង(Copy) កូដទាំងនោះមកដាក់នៅលើWidgets របស់យើង តែពេលនេះ យើងសូមលើកយកកម្មវិធីមួយដែលមានការពេញនិយមក្នុងការប្រើប្រាស់។ ដំបូងយើងត្រូវតំឡើងPlugin មួយសិនដែលមានឈ្មោះថា Black Studio TinyMCE




ពេលនេះខ្ញុំនិងប្រើប្រាស់ Plugin នេះដើម្បី ដាក់បញ្ចូលនៅរូបភាព ក៏ដូចជា កូដHTML ជាដើម។ដំបូងចុចលើAdd Media -> ជ្រើសយករូបភាព ->Inert into post




ហើយបន្ទាប់មក ចុចSave ជាការស្រេច។



# ២០.របៀបប្រើប្រាស់Facebook Plugin

ដើម្បីឲ្យមានភាពងាយស្រួល ដល់អ្នកដែលចូលទៅទស្សនាលើSite របស់យើង គឺយើងត្រូវបន្ថែមនូវប្រព័ន្ធបណ្តាញសង្គម ដូចជា Facebook, Twitter,Skype ជាដើម។ដូចនេះយើងសូមលើកយក plugin មួយឈ្មោះថា Facebook ដែលក្នុងនោះមានដូចជា Facebook Like box, Facebook Comment Box, Facebook Recommend bar ។ដើម្បីប្រើយើងត្រូវ តម្លើង Plugin មួយឈ្មោះថាFacebook។ បន្ទាប់មកទៀត ចុចលើ Facebook Setting Menu -> General វានិងបង្ហាញដូចខាងក្រោម៖







បន្ទាប់មកទៀតយើងត្រូវបញ្ចូលនូវ App ID និង App secret ដើម្បីបានរបស់ទាំងនេះយើងត្រូវមាន Facebook Page មួយសិន បន្ទាប់មកយើងចុចលើ **Creat a new Facebook Application or associate New WordPress** ... នោះវានិងបង្ហាញ App ID និង App secret របស់យើង ចូរចម្លងវា ហើយដាក់ក្នុងប្រអប់ឲ្យបានត្រឹមត្រូវ។






## ក.Facebook Like Button(ប៊ូតុងចូលចិត្ត)




- Show on :ទីកន្លែងដែលត្រូវបង្ហាញ
- Postion :ទីតាំងរបស់ប៊ូតុង
- Width :ប្រវែងទទឹង
- Font :ទម្រង់អក្សរ

## ខ.Facebook Send Button(ប៊ូតុងផ្ញើរអត្ថបទ)




ចំនុចទាំងប៉ុន្មាននេះគឺដូចទៅនឹង Facebook Like Button ដែរ

## គ.Facebook Follow Button(ប៊ូតុងតាមដាន)




ចំនុចទាំងប័ន្មាននេះគឺដូចទៅនឹង Facebook Like Button ដែរ

## ឃ.Facebook Comment Box(ប្រអប់មតិ)




នេះគឺជាលទ្ធផល



<u>យោងតាម៖</u>

1. ITKonkhmer.com
2. Google.com
3. Youtube.com

<u>ទំនាក់ទំនង៖</u>

បើសិនមានការខុសឆ្គង ខ្ញុំបាទសូមអភ័យទោសផង ព្រោះតែពុំបានផ្ទៀងផ្ទាត់ឲ្យបានល្អិតល្អន់ បើមានជាមតិរិះគន់ដើម្បីស្ថាបនា សូមធ្វើការទាក់ទងតាម៖

- Nokormusic.com
- Facebook: Chheangen
- Twitter.com/chheangen
- Tel: 097 6654498

សូមអរគុណ!